

# តើសេចក្តីប្រកាសនៃភាពជាឪពុកអាចជួយចំពោះលោកអ្នកនិងកូនខ្មែរបៀបណា?

**តើ *សេចក្តីប្រកាសនៃភាពជាឪពុក*គឺជាអ្វី?**

*សេចក្តីប្រកាសនៃភាពជាឪពុក* (Declaration of Paternity) គឺជាឯកសារច្បាប់មួយដែលថា បុរសនោះគឺជាឪពុកបង្កើតនៃក្មេង នៅពេលណាដែលឯកសារនេះត្រូវបានចុះហត្ថលេខាដោយឪពុកនិងម្តាយ ។ ការចុះហត្ថលេខានៅលើ*សេចក្តីប្រកាសនៃភាពជាឪពុក*នេះ គឺជាការស្ម័គ្រចិត្ត ។

**តើ *សេចក្តីប្រកាសនៃភាពឪពុក*អាចជួយចំពោះយើងរបៀបណាខ្លះ?**

នៅពេលឪពុកម្តាយក្មេងមិនបានរៀបអាពាហ៍ពិពាហ៍នៅពេលចាប់ផ្តើមមានផ្ទៃពោះ ឬនៅពេលកំណើតក្មេង ឪពុកក្មេងអាចមិនត្រូវបានគេចាត់ទុកថាជាបិតាពេញច្បាប់ ដែលគាត់មានសិទ្ធិ ឬមានការទទួលខុសត្រូវចំពោះក្មេងនោះឡើយ ។
អ្នកអាចចុះហត្ថលេខានៅលើ*សេចក្តីប្រកាសនៃភាពជាឪពុក* ដើម្បីជួយឱ្យឪពុកមានសិទ្ធិតាមផ្លូវច្បាប់ជាឪពុករបស់ក្មេង ។ នៅពេលដែលឪពុកម្តាយទាំងពីរនាក់ចុះហត្ថលេខា សំណៅនេះនឹងបង្កើតជាទំនាក់ទំនងនៃឪពុកម្តាយនិងកូនតាមផ្លូវច្បាប់ រវាងឪពុកហើយនិងកូន ។

**ហេតុអ្វីបានជាយើងគួរតែចុះហត្ថលេខានៅលើសេចក្តីប្រកាស?**

ដើម្បីបង្ហាញកូនថា លោកអ្នកមានសេចក្តីពេញចិត្តជាឪពុកម្តាយរបស់កូនប្រុសឬកូនស្រីនោះ ?

ដើម្បីបង្កើតតាមផ្លូវច្បាប់ថាបុរសនោះគឺជាឪពុករបស់ក្មេង ។

ដើម្បីអនុញ្ញាតឱ្យគេបញ្ចូលឈ្មោះឪពុកទៅក្នុងសំបុត្រកំណើតនៃកូនរបស់លោកអ្នក ។

ដើម្បីអនុញ្ញាតឱ្យគេបញ្ចូលឈ្មោះកូនរបស់លោកអ្នកនៅក្នុងគ្រោងការធានាសុខភាពរបស់ឪពុក ។

ដើម្បីជួយធ្វើឱ្យប្រាកដថា ផលកំរៃសន្តិសុខសង្គម ឬអតីតយុទ្ធជនត្រូវបានបង់ទៅឱ្យកូនរបស់លោកអ្នកនៅក្នុងករណីដែលឪពុកស្លាប់ ឬពិការ ។

ដើម្បីជួយការពារនូវសិទ្ធិនៃកូនរបស់លោកអ្នកក្នុងការទទួលមរតកពីឪពុក ។

**តើមានន័យយ៉ាងណានៅពេលដែលយើងចុះហត្ថលេខានៅលើសេចក្តីប្រកាស?**

បន្ទាប់ពីឪពុកម្តាយទាំងពីរនាក់បានចុះហត្ថលេខានៅលើសេចក្តីប្រកាស និងសំណៅនេះត្រូវបានដាក់ស្នើទៅក្រសួងសង្គមកិច្ចនៃរដ្ឋកាលីហ្វ័រនីញ៉ា (California Department of Social Services) សំណៅនេះបង្កើតជាទំនាក់ទំនងនៃឪពុកម្តាយនិងកូនតាមផ្លូវច្បាប់រវាងឪពុកហើយនិងកូន ។ នៅគ្រាដែលភាពជាឪពុកត្រូវបានបង្កើតឡើងហើយ ឪពុកនឹងមានសិទ្ធិតាមច្បាប់ និងការទទួលខុសត្រូវផ្នែកប្រាក់កាសក្នុងឋានៈជាឪពុកម្តាយនៅក្រោមច្បាប់នៃរដ្ឋកាលីហ្វ័រនីញ៉ា ។ ដោយការចុះហត្ថលេខានៅលើសេចក្តីប្រកាសនេះនឹងផ្តល់ឱ្យឪពុកនូវសិទ្ធិជាឪពុកម្តាយ ដើម្បីស្វែងរកនូវភាពជាអ្នកអាណាព្យាបាល ឬការមកសួរសុខទុក្ខតាមច្បាប់នៅតុលាការ និងដែលត្រូវបានទទួលការពិភាក្សាចំពោះការទុកដាក់ក្មេងឱ្យគេចិញ្ចឹម ។

**តើយើងអាចបដិសេធ ឬទុកជាមោឃៈនូវសេចក្តីប្រកាសបន្ទាប់ពីយើងបានចុះហត្ថលេខារួចហើយនោះ?**

ឪពុកឬក៏ម្តាយអាចទុកជាមោឃៈ ឬបដិសេធនូវ*សេចក្តីប្រកាសនៃភាពជាឪពុក*បានដោយការបំពេញសំណៅបដិសេធសំរាប់សេចក្តីប្រកាសនៃភាពជាឪពុក ហើយដាក់ស្នើទៅក្រសួងសង្គមកិច្ចនៃរដ្ឋកាលីហ្វ័រនីញ៉ានៅក្នុងរយៈពេល៦០ថ្ងៃ ចាប់តាំងពីកាលបរិច្ឆេទដែលបានចុះហត្ថលេខានៅលើសេចក្តីប្រកាស ។ សំណៅសំរាប់បដិសេធនេះមាននៅការិយាល័យជួយផ្គត់ផ្គង់គ្រួសារនៃមេធាវីតំបន់ ឬនៅការិយាល័យចុះឈ្មោះកើតនិងស្លាប់នៅក្នុងតំបន់ ។

**តើយើងបំពេញសេចក្តីប្រកាសតាមរបៀបណា?**

ផ្នែកA និង B គួរតែបានបំពេញដោយឪពុកម្តាយក្មេង ។ សាក្សីនឹងបំពេញនៅក្នុងផ្នែកC ។ សូមអានរបៀបបំពេញនៅក្នុងសេចក្តីប្រកាសសំរាប់ពត៌មានបន្ថែមយ៉ាងល្អិតល្អន់ ។

**តើយើងត្រូវធ្វើយ៉ាងណាបើសិនជាយើងមានសំណួរបន្ថែម?**

សំរាប់ពត៌មានបន្ថែមអំពី*សេចក្តីប្រកាសនៃភាពជាឪពុក* ការបង្កើតឱ្យមានភាពជាឪពុកម្តាយ ឬកិច្ចជួយផ្គត់ផ្គង់កូន សូមទាក់ទងការិយាល័យជួយផ្គត់ផ្គង់គ្រួសារនៃមេធាវីតំបន់ដែលនៅក្នុងតំបន់ ការិយាល័យជួយសម្របសម្រួលផ្នែកច្បាប់សំរាប់គ្រួសារ ឬអង្គការផ្តល់ជំនួយផ្នែកច្បាប់ ។

PATERNITY OPPORTUNITY PROGRAM